# ការសំភាសន៍របស់អ្នកមីងធូ ចាន់ថុល

កៈ អ្នកដែលសំភាសន៍ញ៉ែម សុគន្ធា ខៈ អ្នកដែលត្រូវគេសំភាសន៍ឈ្មោះធូ ចាន់ថុល

## ការសង្ខេបរបស់អ្នកមីងធូ ចាន់ថុល

អ្នកមីង ធូ ចាន់ថុល ជាអ្នកស្រុកស្អាង នៅភូមិកោះគរ ដែលកោះគរហ្នឹងកាលពីសម័យប៉ុលពតគឺជាមន្ទីរ០៨ដែលគេសម្លាប់មនុស្ស។
អ្នកមីងមានបងប្អូន៩នាក់ហើយគាត់បានប្រាប់ថាបងប្អូនគាត់ពុំសូវជិតស្និតគ្នាប៉ុន្មានទេ!!
ឪពុកម្ដាយអ្នកមីងជាអ្នកប្រកបរបរធ្វើស្រែចំការ
ហើយគាត់ប្រាប់ថាម្ដាយគឺជាអ្នកមានគួរសមពីសម័យដើមប៉ុន្តែដល់ពេលសម័យប៉ុលពតម្ដាយហើយនឹងឪពុកគឺបានបែកគ្នាហើយឪពុកត្រូវគេយកទៅសម្លាប់នៅឆ្នាំ១៩៧៨ ដោយព្រោះគេដឹងថាគាត់ជាពេទ្យហើយម្ដាយបានរងទុក្ខជាខ្លាំងហើយពេលហ្នឹងគាត់បានស្លាប់កូនមួយទៀត ជីដូនជីតាគាត់គឺជាមនុស្សល្អដែលអ្នកស្រុកស្រលាញ់រាប់អាន។

កៈ
ជាដំបូងនាងខ្ញុំសូមថ្លែងអំណរគុណដល់អ្នកមីងដែលអោយញ៉ុមសំភាសន៍អំពីជីវប្រវត្តិរបស់អ្នកមីង នាងខ្ញុំឈ្មោះញ៉ែម សុគន្ធា ជាអ្នកសំភាសន៍អំពីជីវប្រវត្តិរបស់អ្នកមីងនៅក្នុងថ្ងៃនេះហើយពួកយើងសំភាសន៍គឺនៅក្នុងខែមិនា ឆ្នាំ២០១៨ ការសំភាសន៍មានទីតាំងស្ថិតនៅក្នុងភូមិកោះគរ ឃុំរកាខ្ពស់ ស្រុកស្អាង ខេត្តកណ្ដាល
ប្រទេសកម្ពុជា។អ៊ីចឹងនាងខ្ញុំសូមចាប់ផ្ដើមសំភាសន៍អំពីជីវប្រវត្តិរបស់អ្នកមីងមានដូចតទៅ អ្នកមីងសូមប្រាប់ឈ្មោះពេញមើលអ្នកមីងឈ្មោះអីគេដែរ?

ខៈ ញ៉ុមឈ្មោះ ធូ ចាន់ថុល។

កៈចាំ អ្នកមីងសព្វថ្ងៃអាយុប៉ុន្មានហើយ?

ខៈ អាយុ៥១។

កះ ៥១ឆ្នាំហើយអ្នកមីងណោះ?

ខះចាំ!!

កះ សំរាប់អ្នកមីងពេលនៅពីក្មេងមកមានអ្នកណាហៅឈ្មោះអីផ្សេងក្រៅពីចាន់ថុលទេ?

ខះ អត់ទេអត់ដែលមានទេ!!

កះ ចុះម៉ែមានដាក់ងារអីអោយអត់អ្នកមីង?

ខះ អត់ អត់សោះ!!

កះចាំហ្នឹងហើយ!!!ចាំអអញ្ចឹងគេហៅចាន់ថុលតាំងពីក្មេងមក?

ខះ ចាំគេហៅតាំងពីក្មេងមក។

កះ ចាំមីងឆ្នាំខ្មែរអ្នកមីងកើតឆ្នាំអីគេវិញ?

ខះ ឆ្នាំមមែ!!

កះឆ្នាំមមែហេ?

ខះចាំ!!

កះចុះដល់ពេលឆ្នាំបារាំងអ្នកមីងកើតពេលណាវិញ?

ខះ ១៩៦៦។

កះ ចាំ!!ថ្ងៃខែអីអត់?ថ្ងៃទីខែអីអញ្ចឹងហាំ??

ខះ ខែមើលក្នុងនេះ!!

កះ មើលក្នុងអត្តសញ្ញាបណ្ណ័មីងហេ?នេះអ្នកមីងហេ?

ខះ ចាំហ្នឹង!!

កៈអ្នកនៅក្មេង!! ចាំអញ្ជឹងអ្នកមីងនៅក្នុងអត្តសញ្ញាបណ្ណ័ដាក់ធូ ចាន់ថុល
ថ្ងៃខែឆ្នាំកំនើតថ្ងៃទី០៧ ខែ០៤ ១៩៦៦
អញ្ជឹងទីកន្លែងកំណើតអ្នកមីងនៅឯណាវិញអ្នកមីងអាចប្រាប់?

ខៈ នៅរកាខ្ពស់ហ្នឹងម៉ង ស្រុកស្អាងហ្នឹង។

កៈចាំអញ្ជឹងនៅក្នុងភូមិឃុំដែលនៅសព្វថ្ងៃហ្នឹង?

ខៈចាំ!!

កៈ អញ្ជឹងអ្នកមីងពីដើមមកផ្ទះនៅហ្នឹងឬក៏នៅឯណាផ្សេង?

ខៈ ផ្ទះពីដើមអើយតាំងពីពីជីដូនជជីតាមកនៅហ្នឹងម៉ងអត់មានទៅណាទេ!!

កៈចាំ អញ្ជឹងម៉ែ កើតមកដឹងតែឃើញនៅហ្នឹងម៉ង?

ខៈ នៅឃើញស្រុកហ្នឹងទាំងអស់!!

កៈចាំ!!ហ្នឹងហើយ អ្នកមីងគឺទីកន្លែងកំណើតគឺនៅហ្នឹងម៉ង!!

ខៈចាំ!!

កៈហើយបងប្អូនស្រីប៉ុន្មានប្រុសប៉ុន្មានដែរ?

ខៈ បងប្អូន៤នាក់ស្រី២ប្រុស២។

កៈ ស្មើគ្នាទៀត ហើយមីងជាកូនទីប៉ុន្មានវិញ?

ខៈ ជាកូនទី២។

កៈ
អ្នកមីងអញ្ជឹងបងប្អូនទាំងអស់គ្នាតើគាត់រស់នៅទាំងអស់គ្នាឬក៏មានអ្នកណាគេខ្លះអនិច្ចាកម្ម ខ្លះហើយ?

ខៈ ស្លាប់មួយ។ស្លាប់បងប្រុស!!

កៈ ហើយគាត់ស្លាប់មូលហេតុអីគេវិញ?

ខៈ ស្លាប់ឈឺលើសឈាម។

កៈទឹមតែឥលូវៗហ្នឹងតើហេ?

ខៈស្លាប់៧ឆ្នាំហើយ!!

កៈ ចាំហ្នឹងហើយ!!បងប្អូនទាំង៤នាក់ហ្នឹងហេ?

ខៈចាំ!!

កៈពីក្មេងមកចូលចិត្តលេងអីគេជាមួយគ្នាជាងគេ?

ខៈអើយបើការពិតទៅបងប្អូនញ៉ុមមិនសូវត្រូវគ្នាទេ ។

កៈម៉េចអីចឹងវិញ?

ខៈ អត់សូវត្រូវគ្នាមិនដឹងជាយ៉ាងម៉េច!!

កៈ ហើយទៅអញ្ចឹងវិញទៅ?

ខៈ អត់ដឹង!!ហ្នឹងនិយាយអោយត្រង់ម៉ងហាំ!!

កៈ អ៊ិចឹងភាគច្រើននៅបែកគ្នាហេ?

ខៈ នៅបែកគ្នាម៉ង!!

កៈ ហើយចុះបងស្រីឬក៏ប្អូនស្រី?

ខៈ បងប្រុស។

កៈចុះស្រីប្អូនទេហី?

ខៈ ស្រីប្អូនពៅ!!

កៈតែអត់សូវស្និតស្នាលជាមួយគ្នាដែរ?

ខ៖ចាំ!!

ក៖ម៉េចអ៊ីចឹងវិញអ្នកមីង?

ខ៖ មិនដឹងជាយ៉ាងម៉េច!!មិនដឹងយ៉ាងម៉េច!!

ក៖ ហើយដល់ពេលអញ្ជឹងម៉េច!!ហើយដល់ពេលនៅពីក្មេងមកលេងអីគេជាមួយគ្នា?

ខ៖ ពីក្មេងមកហោ?

ក៖ចាំ!!

ខ៖ពីក្មេងមកទៅរៀនទៅអីជាមួយគ្នាអ៊ិចឹងទៅ
ទៅមកវិញដូចថាអាហីអាហីរៀងខ្លួនទៅ!!ដូចថាមិនសូវមិនបានលេងសើចអីជាមួយបងប្អូនប៉ុន្មានទេ!!

ក៖ចាំ!!

ខ៖ហ្នឹងហើយ!!

ក៖ ចុះគិតថាពេលអនុស្សាវរីយ៍ពេលដែលស្និតស្នាលជាងគេពេលណាវិញមីង?

ខ៖ អនុស្សាវរីយ៍ដែលស្និតស្នាលជាងគេពេលដែលនឹកឃើញម្តងៗពេលជំនាន់អាពត!!

ក៖ ម៉េចវិញទៅអ្នកមីង?

ខ៖អាហ្នឹងនឹកឃើញថាកំសត់អ៊ិចឹងទៅមកអញ្ជឹងទៅឪពុកគេយកទៅសម្លាប់ចោលម៉ែមកមេម៉ាយអញ្ជឹងទៅមកចិញ្ចឹមបងប្អូនអញ្ជឹងទៅ!!
តែញ៉ុមម៉ាបងប្អូនទាំងអស់ញ៉ុមនឿយជាងគេ!!ក៖ហ៊ឺ!!

ខ៖ញ៉ុមហាត់នឿយជាងគេ!!

ក៖ ម៉េចដដែរអ្នកមីងជីវិតពេលហ្នឹងម៉េចបាននឿយ?

ខ៖ជីវិតពេលហ្នឹងខ្ញុំកំសត់ជាងគេហើយញ៉ុមហាត់នឿយជាងគេបំផុតព្រោះអីញ៉ុមអត់សូវបានរៀនសូត្រទេ ប្អូនបងគេរៀនទាំងអស់ញ៉ុម

បើញ៉ុមនិយាយរួមទៅញ៉ុមដើរស៊ីឈ្នួលគេធ្វើការធ្វើស្រែតែពីរនាក់ម្ដាយអ៊ីចឹងទៅ ហើយជូនកាលម្ដាយទៅជួយទៅហើយជូនកាលអត់ទៅ យាយជរាមួយនៅផ្ទះអញ្ចឹងទៅ ញ៉ុមដើរស៊ីឈ្នួលគេលក់នំ
លក់អីគេអញ្ចឹងទៅលក់នំតាមផ្ទះតាមអីអញ្ចឹងទៅចិញ្ចឹមប្អូនអញ្ចឹងទៅ ម៉ែអញ្ចឹងទៅ យកលុយអោយប្អូនរៀនអញ្ចឹងទៅ!!

ក៖ចាំ!!ហើយពួកគាត់អត់ជួយអញ្ចឹងទេចុះ?

ខ៖ អត់ទេ ប្អូនញ៉ុមមីមួយពៅគេនោះស្រណុកជាងគេបំផុត។

ក៖ ផ្ទះនៅជិតហ្នឹងដែរតើអ្នកមីង?

ខ៖ ផ្ទះនៅជិតដែរ។

ក៖អញ្ចឹងបងប្អូនអ្នកមីងអើរឥឡូវនៅតែពីរនាក់ទៀតតើហី?មួយទៀតស្លាប់បាត់ហើយ?

ខ៖ស្លាប់ហើយនៅពីរនៅបីទាំងញ៉ុម។

ក៖ ចាំពួកគាត់ប្រកបរបរអីគេដែរអ្នកមីងចិញ្ចឹមជីវិត?

ខ៖អើយសព្វថ្ងៃហ្នឹងប្ដីវាដាក់រកធ្វើជានេសាទ
ហើយប្រពន្ធហ្នឹងកសិករដើរស៊ីឈ្នួលធ្វើស្មៅបន្លែធ្វើអីអោយគេហ្នឹងទៅ។

ក៖ចាំ!

ខ៖ ហ្នឹង!!

ក៖អត់មានដីដាំចំការខ្លួនឯងទេហេ?

ខ៖ អត់មានទេ អូនអត់មានទេ។

ក៖ចុះដល់ពេលបងប្រុសមួយទៀតអ្នកមីង?

ខ៖ ប្អូនប្រុសមួយទៀតអាហ្នឹងមានមុខរបរគេមួយទៀតនៅស្រែអំបិលហ្នុ៎!!នៅកោះកុង!!

ក ៖កោះកុង!!

ខ៖ចាំ!!

ក៖អាស្ពានបំបែកទៅកំពង់សោមកោះកុងហ្នឹងហេ?

ខ៖ ហ្នឹងហើយកោះកុងហ្នឹង ហ្នឹងហើយនៅស្រែអំបិលហ្នឹង!!

ក៖គាត់ធ្វើអីគេអ្នកមីង?

ខ៖ គេអើរធ្វើពេទ្យ។

ក៖ ហ៊ីខ្លាំង រៀនបានទៅដល់តែធ្វើពេទ្យ។

ខ៖ ធ្វើពេទ្យ។

ក៖ហើយគេមានជួយធ្វើអីគេខ្លះដល់មីងទេ?

ខ៖ អត់សោះ អត់មានដែលសូម្បីតែមកអើតអត់ដែលផង។

ក៖ទៅអញ្ចឹងវិញទៅ!!

ខ៖ ហ្នឹងហើយ!!

ក៖ ហើយដូចមីងនិយាយមែន។

ខ៖ហ្នឹងអត់ដែលមកអើតទេ!!

ក៖ តាំងពីការមេកអត់ដែលសោះម៉ងហេ?

ខ៖អត់សុទ្ធម៉ងបងប្អូនញ៉ុម។

ក៖ ហើយមីងដែលទៅលេងអត់អញ្ចឹង?

ខ៖ ញ៉ុមធ្លាប់ទៅតែគេអត់ស្តីអត់និយាយរកញ៉ុមក៏ត្រលប់មកវិញមក!!ក៖ហា!!!ខ៖ញ៉ុមទៅជាមួយកូនញ៉ុមអាទី២ហ្នឹងអត់សូវដែលនិយាយអត់សូវស្តីនិយាយរកទេ!!

ក៖ បងប្អូនខ្លួនឯងបង្កើតសោះហ្នឹង?

ខ៖ ហ្នឹងហើយ គេវាមានជាងយើងយើង វាក្រ!!

ក៖ ហើយចុះ ហើយអញ្ចឹងវាម៉េចទេមីងហាំ!!!ម៉េចអញ្ចឹងទេពូហ្នឹង!!!អ្នកមីងខំទៅរាប់អានហើយហោ?

ខ៖ យើងក្រ !!ចាំ!!យើងទៅយើងទៅយើងអត់ចោលទេ នឹកឃើញថាបងប្អូនសាច់ហាំទងសុកម្ដាយតែមួយហាំ!!

ក៖ចាំ!!

ខ៖អត់ពីម្ដាយទៅយើងបងយើងមើលការខុសត្រូវ!!តែចំពោះគេប្អូនគេមិនចាំបាច់ថាអោយខ្វល់ទេ !!

ក៖តែគាត់បានរៀនដល់ថ្នាក់ធ្វើពេទ្យហ្នឹងដោយសារមីងទេអញ្ចឹង?

ខ៖ ហ្នឹងហើយរៀន រៀនសូត្រពីមុនមកញ៉ុមអ្នករកអ្នកស៊ីឈ្នួលគេចេះតែចិញ្ចឹមប្អូនទៅសូម្បីតែសំលៀកបំពាក់ញ៉ុមរកស្លៀកគ្នានផង!!

ក៖ហ៊ឺ!!

ខ៖ ពេលមានរវល់ការកូនគេការនៅភូមិក្នុងឃុំអញ្ចឹងទៅញ៉ុមមិនដែលមានស្លៀកពាក់ទេ។

ក៖ ហ្នឹងហើយ!!អើយដល់ពេលអញ្ចឹងមិនដឹងគិតយ៉ាងម៉េចដែរ តែដល់ពេលអញ្ចឹងប្អូនស្រីនៅជិតគ្នាហ្នឹងអត់អីទេ?

ខ៖ នៅជិតគ្នាតែក៏មិនធម្មតាដែរ។

ក៖ម៉េចវិញទៅមីង?

ខ៖ ក៏មិនធម្មតាដែរ ហ្នឹងញ៉ុមមិននិយាយថាចេះហៃហកកេរ្តិ៍បងប្អូនទេណាស់ ការពិតវាអញ្ចឹងមែន។ក៖ចាំ!!ខ៖អត់សូវត្រូវទេ!!

ក៖ តែរកពឹងពាក់គ្នាអីគេបានទេមីង?

ខ៖ អត់បានទេអូន បើគេពឹងយើងបាន!!

ក៖មីងអោយអ៊ីចឹងទៅ?

ខ៖ចាំ!!

ក៖ដល់ពេលរកគាត់អត់បានទេ?

ខ៖អត់បានទេ!!

ក៖ កុំសង្ស៊ឹមហោ?

ខ៖ កុំសង្ស៊ឹម!!

ក៖ ឥឡូវមីងរកស៊ីអីគេប្អូនស្រី?

ខ៖ ប្អូនហ្នឹងប្តីគេធ្វើនេសាទ!!

ក៖ហ្ហូហ្នឹងហើយៗអ្នកមីងប្រាប់មិញដែរ!!

ខ៖ហ្នឹងហើយ!!

ក៖ចាំ!!ហើយអ្នកមីងថាដូចពេលណាដែលអត់ត្រូវគ្នាអត់ចុះតែមានពេលណាដែលទន់ភ្លន់ដាក់គ្នា មីងជិតស្និតជាមួយជាងគេអ្នកណាគេវិញទៅ?

ខ៖ ជិតស្និតជាងគេ!!

ក៖ ម៉ាបងប្អូនហា?

ខ៖ ម៉ាបងប្អូនទាំងអស់ម៉ងហោ?

ក៖ចាំ!!

ខ៖មានតែមីមួយហ្នឹង អើរក្រែងថាអើរមានម្តងម្កាលអ៊ីចឹសងទៅមានរវល់មានធុរៈអីអញ្ចឹងទៅដូចថាវាចេះតែប្រាប់អញ្ចឹងទៅបងប្អូនជួយមើលជួយមើលការខុសត្រូវអីអញ្ចឹងទៅណាស់!!

ក៖ចាំ!!

ខ៖ហើយអាហីធម្មតាទៅ!!

ក៖ហើយធម្មតាអីចឹងទៅនៅរៀងៗខ្លួនអញ្ចឹងទៅហី?

ខ៖ចា៎!!

ក៖ចា៎!!មីងអើរសំរាប់ពេលនៅពីតូចដូចពួកគាត់សុទ្ធតែនៅក្នុងសង្គ្រាមជាមួយអ្នកមីងដែរទាំងអស់ហេ?

ខ៖ចា៎!!

ក៖ សុទ្ធតែអ្នកកើតមុនសង្គ្រាមទាំងអស់?

ខ៖ចា៎!!

ក៖ដល់ពេលនៅជំនាន់ប៉ុល ពតហ្នឹងពួកគាត់នៅជាមួយអ្នកមីងឬក៏នៅបែកៗពីគ្នា?

ខ៖ នៅបែកៗពីគ្នា!!

ក៖ បែកពីគ្នាអញ្ចឹងទៅ!!!

ខ៖ ដូចថាបំបែកចេញរៀងៗខ្លួនទៅម្ដាយដោយខ្លួនកូនដោយខ្លួនទៅ!!ប្អូនបងរៀងខ្លួនបែកចេញពីគ្នាទាំងអស់!!!

ក៖ តែអត់ព្រាត់ប្រាណគ្នាដែលអ្នកមីងណោះនៅមានជីវិតទាំងអស់គ្នា?

ខ៖ បងប្រុសញ៉ុមមួយស្លាប់ហ្នឹងនៅអង្គភាពទូលក្រសាំង ញ៉ុមនោសិត្ស ម្ដាយនៅទឹកវិល!!

ក៖ អញ្ចឹងជិតៗគ្នាទេហេ?

ខ៖ មិន មិនជិតទេណាស់!!

ក៖ ដើរមួយហាត់!!

ខ៖ ម្ដាយញ៉ុមបញ្ជូនទៅទឹកវិលហា៎!!នៅឃុំទឹកវិលហា៎!!

ក៖ ឆ្ងាយហេមីងពីហ្នឹងទៅ?

ខ៖ ចាំចុះយើងពីយើងរកាខ្ពស់ទៅទឹកវិលវំលងប៉ុន្មានឃុំប៉ុន្មានឃុំតែគ្រាន់តែនៅក្នុងស្រុកស្អាងទេ!!

ក៖ចាំ!!

ខ៖ ហ្នឹង!!

ក៖ អញ្ចឹងស្រុកស្អាងធំមីងណោះ?

ខ៖ចាំគេបញ្ជូន!!

ក៖ ចាំហើយដល់ពេលបញ្ជូនទៅឆ្ងាយៗដាច់ពីគ្នាអ៊ីចឹងទៅ?

ខ៖ហ្នឹងហើយ!!

ក៖អញ្ចឹងអ្នកមីងសំរាប់ម្ដាយរបស់អ្នកមីងគាត់ឈ្មោះអីគេដែរ?

ខ៖ ឈ្មោះឃូ សាក់។

ក៖ ឃូ សាក់?

ខ៖ចាំ!!

ក៖ ឥឡូវគាត់នៅមានជីវិតទេ?

ខ៖ ឥឡូវគាត់ស្លាប់បាត់ហើយ!!!

ក៖ ហាហ៊ឺ!!ស្លាប់តាំងពីឆ្នាំណាវិញមីង?

ខ៖ ស្លាប់តាំងពីឆ្នាំ២០០៨។

ក៖ ហ៊ឺ!!យូរដែរហើយ!!

ខ៖ចាំ!!!

ក៖ អ៊ិចឹង១០ឆ្នាំជាងហើយ!!គាត់ស្លាប់មូលហេតុអីអ្នកមីង?

ខ៖ គាត់ឈឺ។

ក៖ ជំងឺចាស់ជរាហី?

ខ៖ ជំងឺគាត់ ជំងឺ បើគិតទៅ ជំងឺតំរងនោមហើយនឹងលើសឈាមហើយនឹងទឹកនោមប្រៃ!!

ក៖ច្រើន!!

ខ៖ ចាំ!!

ក៖ គ្រប់មុខហើយ!!ហ្នឹតងហើយពមុខហ្នឹងហើយធ្វើអោយគាត់ស្លាប់អញ្ចឹងទទៅ!!

ខ៖ចាំ!!

ក៖ពេលគាត់ស្លាប់ហ្នឹងគាត់អាយុប៉ុន្មានដែរអ្នកមីង?

ខ៖ គាត់អាយុ៦០គត់។

ក៖ ៦០គត់ហើយ!!ទឹមដែរហ្នឹងអញ្ចឹង?

ខ៖ចាំ!!

ក៖ម៉ែញ៉ុមអាយុ៦០គត់ហើយរៀងនៅក្មេងដែរហ្នឹងមីង?

ខ៖ចាំ!!គាត់ខូច!!

ក៖
ចាំ!!អញ្ចឹងអ្នកមីងនិយាយរៀបរាប់ពីជីវិតរបស់ម្ដាយរបស់អ្នកមីងតិចមើលអ្នកមីងដឹងអីគេខ្លះពីជីវិតរបស់គាត់ អ្នកមីងរៀបរាប់អោយបានក្បោះក្បាយពីជីវិតរបស់គាត់អញ្ចឹងទៅណាស់?

ខ៖ ជីវិតម៉ាក់ញ៉ុមហោ?

ក៖ចាំ!!

ខ៖ ជីវិតម៉ែញ៉ុមគាត់រស់សុខស្រួលពីសង្គមចាស់ទេ តែពីសង្គមចាស់ហ្នឹងក៏គាត់អត់សូវសុខស្រួលប៉ុន្មានដែរ គាត់ពិបាករហូត

គាត់កូនអ្នកមីងមួយដែរក៏ប៉ុន្តែគាត់អត់មានថា
ដូចគាត់អត់មានថាបានស្រណុកសុខស្រួលដូចគេទេណាស់
គាត់មានគ្រួសារទៅអាហ្នឹងញ៉ុមធំដឹងក្តីញ៉ុមដឹងគ្រាន់ថាបងប្អូនខាងប្តីមកបងថ្លៃប្អូនថ្លៃមកជុំគ្នា ២៥មាត់ ១៥នាក់អញ្ចឹងម្តាយញ៉ុមជ្រោងទាំងអស់។

កៈហ៊ឺៗ!!

ខៈអញ្ចឹងដូចគាត់ថាការស្រណុកសុខស្រួលដូចគេទេអញ្ចឹងហាំ!!

កៈហ៊ឺៗ!!

ខៈបើនិយាយទៅម៉ែញ៉ុមគាត់កំសត់ណាស់។

កៈ ម៉េចគាត់កំសត់ម៉េចទៀតមីង?

ខៈ គាត់កំសត់ត្រង់ថា ពីសង្គមចាស់មកគាត់នៅជុំប្តីជុំកូនមែន ប៉ុន្តែដូចថាមានភាពកក់ក្តៅប៉ុន្តែមិនសូវសប្បាយចិត្ត ហ្នឹងបើហ្នឹងយើងនិយាយទៅគាត់មានតែភាពកក់ក្តៅតែចិត្តមិនសប្បាយហាំ!! ដល់មកចូលជំនាន់ប៉ុល ពតទៀត គេបំបែកគាត់រហូត!!ចុះពីឆ្នាំ៧៥(១៩៧៥)មក គាត់ពោះធំប្អូនពៅញ៉ុមមួយទៀត ដល់តែពេលពោះធំប្អូនញ៉ុមញ៉ុមឆ្លងទន្លេហើយគេបំបែកឪញ៉ុមរហូត ទាល់តែគេយកឪញ៉ុមទៅសម្លាប់ចោលឆ្នាំ៧៨(១៩៧៨)។

កៈអូ អញ្ចឹងឪពុកអ្នកមីងស្លាប់ចោលនៅក្នុងជំនាន់ប៉ុល ពតទេ!!

ខៈ ចាំស្លាប់ឆ្នាំ៧៨(១៩៧៨)!!

កៈ ចាំ ឥឡូវទុកឪពុកសិន ឥឡូវនិយាយពីម៉ែសិនតិចទៀតដល់វគ្គឪពុកម្តាយ!!ម៉េចទៀតមីងចាំអីគេទៀតពីម៉ែទៀត?

ខៈ ហើយដល់តែពេលគេបំបែកគាត់ពេលជំនាន់ប៉ុល ពតហ្នឹងបំបែកគាត់ចេញទៅ ដល់តែរហូតតែគាត់ឆ្លងទន្លេបានកូនហ្នឹងហើយ គេបំបែកប្តីអញ្ចឹងទៅ កូនចាប់ផ្តើមឈឺ កូនពៅហ្នឹងហាំ!!!

ក៖ចាំ!!

ខ៖ ចាប់ផ្តើមឈឺអាពតគេយកទៅយកទៅដេកកន្លែងពេទ្យគេនោះ យកកូនទៅដេកពេទ្យថ្ងៃហ្នឹង អាហ្នឹងគេបញ្ជូនគេបំបែកយាយញ៉ុមនៅភូមិអញ្ចេះ គេបំបែកម្តាយញ៉ុមនៅភូមិបឹងត្នោត ទៅនៅបឹងត្នោតអ៊ីចឹងចឹងទៅដល់តែពេលគេប្រាប់ថាកូនឈឺគេអោយគាត់ឡើងមកយកកូនឡើងមកទៅដេកពេទ្យដេកពេទ្យបាន១០ថ្ងៃ ដំណឹងគេយកម្តាយមីងញ៉ុមទៅសម្លាប់ចោលមុន!!!

ក៖ចំ!!

ខ៖ ហ្នឹងម្តាយមីងញ៉ុមនិស្សិតហាំ!!!

ក៖ហ៊ុំ!!

ខ៖និស្សិតមកពីស្រុកបារាំងម្តាយមីងញ៉ុម !!

ក៖ចំ!!

ខ៖ និស្សិតបញ្ញាវន្តមកពីស្រុកបារាំង!!

ក៖ គេស៊ើបសួរដឹងមីងហេ?

ខ៖ចាំ!!ហើយដល់ពេលហើយគេយកម្តាយមីងទៅសម្លាប់ចោល១០ថ្ងៃគេយក យកឪពុកញ៉ុមទៅសម្លាប់ចោលទៀត គេយកឪពុកញ៉ុមសម្លាប់ចោលបាន១០ថ្ងៃប្អូនញ៉ុមស្លាប់ម៉ែញ៉ុមបដាចាអ៊ីចឹង!!!

ក៖ ហ្នឹងហើយ!!!

ខ៖ តែញ៉ុមសុំសរសើរគាត់ត្រង់គាត់ថាអញ្ចេក គាត់ទប់អារម្មណ៍បានហាំ!! បើក្រៅពីគាត់គាត់ឆ្កួតក៏មិនដឹងដែរ!!ព្រោះមួយខែ៣ហើយ!!

ក៖ ហ្នឹងហើយ!!

ខ៖ ព្រោះប្តីផងកូនផង ប្អូនផង!!ដល់តែពេលគាត់យំពេលមេកងគេហ្នឹងគេមកគេថាម៉េចយំស្រណោះខ្លាំងហោ?គាត់ថាគាត់អត់មានស្រណោះខ្លាំងទេគាត់អានិតកូនគាត់ទឹមតែស្លាប់!!

ក៖ហ៊ឺៗ!!

ខ៖ ថាអញ្ចឹងហា៎!!ហើយដល់ពេល!!

ក៖ តាមពិតគាត់បូករួមនៅក្នុងហ្នឹងទាំងអស់តែអត់និយាយកើត!!

ខ៖ចា៎អត់និយាយកើត!!ហ្នឹងអ៊ីចឹង!!!

ក៖តែប្រាប់ហ្នឹងអ៊ីចឹងទៀតបណ្តោយ!!

ខ៖ ដល់ពេលរំលងបាន១០ថ្ងៃគេចាប់បញ្ជូនទៅទឹកវិល បញ្ជូនទៅកោះខ្យាច់ជន្លាហ្នឹងហា៎!!!

ក៖ចា៎!!!

ក៖ទៅនៅកោះខ្យាច់ជន្លាហ្នឹងគេក៏បំបែកពួកញ៉ុមក៏ចេញអស់ហើយជីដូនញ៉ុមហើយនឹងប្អូនពៅញ៉ុមអាប្រុសអាទីបីហ្នឹងនៅជាមួយយាយញ៉ុមនៅកណ្តាលកោះហ្នុ៎ កោះខ្យាច់ជន្លាហ្នុ៎!!

ក៖ចា៎!!

ខ៖ ម្តាយញ៉ុមនៅដងទង់ម៉ែញ៉ុមគេបំបែក បំបែកហា៎!!បំបែកនៅដងទង់ហើយពួកញ៉ុម!!

ក៖ ដងទង់នៅកោះកុងណោះមឹង?

ខ៖ ដងទង់យើង ដងទង់កោះខ្យាច់ជន្លាហ្នឹង!!

ក៖ ហ្នុ៎មិនមែនដងទង់ណោះទេ!!!

ខ៖មិនមែនទេ!!!ទៅនៅហ្នឹងទៅ
ហើយដល់ពេលម្តាយញ៉ុមឈឺមកដេកពេទ្យមកដេកពេទ្យនៅកោះខ្យាច់ជន្លាហ្នឹងទៀត
ដល់តែពេលហើយអាហ្នឹងខ្ញុំណោះនៅអង្គភាពណោះទេណាស់!!

ក៖ចា៎!!

ខះនៅអង្គភាពណោះនៅសិត្យណោះបានគេចាប់បញ្ជូនទៅតាមក្រោយ ហើយបងញ៉ុមគេបញ្ជូនទៅទួលក្រសាំង ដល់តែពេលដែលវៀតណាមគេចូលមកហ្នឹង អាហ្នឹងបងញ៉ុមគេគៀរទៅបាត់ទៀតហើយហ្នឹង បែកគ្នា៣ ៤ថ្ងៃទៀតបានបានជួបគ្នា !!

កះហ៊ឺៗ!!

ខះ
បើនិយាយវិញប្រវត្តិម៉ែញ៉ុមម៉ាក់ញ៉ុមកំសត់ណាស់!!បែកគ្នារហូតមិនដែលស្គាល់មុខប្ដីម៉េចទេ ត្រឹមតែឆ្នាំ៧៥(១៩៧៥)ចុះទៅអាពតចូលទៅអត់ដែលបានជួបមុខប្ដីម៉េចទេ!!

កះ បែកគ្នា!!

ខះ បែករហូតស្លាប់រៀងខ្លួនម៉ង!!

កះចាំ!!

ខះក្នុងកំឡុង៣ឆ្នាំជាងគាត់អត់មានដែលជួបមុខប្ដីគាត់អត់ដែលមានថាយ៉ាងម៉េចទេ រហូតទាល់តែគាត់ស្លាប់បច្ចុប្បន្នហ្នឹងហា!!

កះ អញ្ចឹងអ្នកមីងសំរាប់ជីវិតម្ដាយអ្នកមីងគាត់ចរិកម៉េចដែរ?

ខះ ម្ដាយញ៉ុមចរិកល្អណាស់!!

កះអត់កាចណាហី?

ខះ អត់ទេ អ្នកស្រុកមួយណាក៏សរសើរគាត់ដែរ អ្នកណាក៏គេស្រលាញ់ដែរ ថ្លៃថ្នូរណាស់!!

កះចាំ!! ស្រុកកំណើតម្ដាយរបស់អ្នកមីងនៅឯណាវិញ?

ខះ ស្រុកកំណើតគាត់នៅកន្លែងហ្នឹងដែរ នៅស្រុក!!

កះ នៅស្រុកហ្នឹងម៉ងហេមីងណោះ?

ខះ ចាំនៅស្រុកហ្នឹង!!

កះ កើតជាគឺនៅហ្នឹងតែម្ដង!!

ខ៖ កើត ចា៎!!

ក៖ អ្នកមីងដូចជាម្តាយអ្នកមីងគាត់រកស៊ីអីគេដែរដើម្បីចិញ្ចឹមអ្នកមីង?ពេលគាត់នៅរស់ហា៎?

ខ៖ ម្តាយញ៉ុមកាលពីគាត់នៅរស់ កាលពីសង្គមចាស់មកគាត់លក់ជ្រក់ស្ពៃ ឪពុកញ៉ុមធ្វើពេទ្យ ធ្វើដុកទ័រ ប៉ុន្តែគាត់ហាត់នឿយ គាត់ចិញ្ចឹងជ្រូកផង លក់ជ្រក់ ដើម្បីចិញ្ចឹមកូនផង ចិញ្ចឹងបងថ្លៃផង ចិញ្ចឹមប្អូនថ្លៃផងនៅជុំគ្នាទាំងអស់!!២៨នាក់។

ក៖ ហើយម៉េចអោយគេចិញ្ចឹមទាំងអស់?

ខ៖ ២៨នាក់។

ក៖ អត់ទៅរកស៊ីទេហោ?

ខ៖ មិនដឹងយ៉ាងម៉េចទេ!! តាំងពីបងថ្លៃ តាំងពីបងថ្លៃបង្កើតតាំងពីបងថ្លៃសាច់ថ្លៃមកទៀត ក្មួយសាច់ថ្លៃហ្នឹងមកទៀត ២៨នាក់!!

ក៖ ហោហើយម៉េចទៅអញ្ចឹង?

ខ៖ មិនដឹងអត់ដឹងអត់យល់ទេ ។

ក៖ ពេលហ្នឹងមីងអាយុប៉ុន្មាន?

ខ៖ ខ្ញុំនៅអាយុ៦ ៧ឆ្នាំចូល ៨ឆ្នាំហើយ នៅផ្សារចាស់ នៅស្ពានចាស់។

ក៖ ហើយពុកអ្នកមីងអត់ថាអីដែរហោដល់ពេលម្លឹងៗពេក?

ខ៖ ឪពុកញ៉ុមអត់ថាអីទេ!!ម៉ែញ៉ុមឪញ៉ុមបើនិយាយរួមទៅស្រីគ្រប់លក្ខ័ហើយ ម៉ែញ៉ុមអត់ចេះលាក់ទៀត។

ក៖ចា៎ ដឹងតែពីរកជួយម៉ង?

ខ៖ ចេះតែជួយម៉ងទៅ ចេះតែជួយប្តីទៅ។

ក៖ ហើយជ្រក់ស្ពៃហ្នឹងជ្រក់ខ្លួនឯងមែនអ្នកមីងហោ?

ខ៖ ជ្រក់ខ្លួនឯង។

ក៖ មីងចេះធ្វើជ្រក់ស្ពៃហ្នឹងតាមម៉េទេ?

ខ៖ចេះ!!!

ក៖ មីងប្រាប់ធ្វើជ្រក់ស្ពៃពេលខ្លះញ៉ុមធ្វើអត់ឆ្ងាញ់ ហើយអញ្ចឹងលោរអ្នកមីងមានវិធីអីដែលដល់ថ្នាក់លក់ហើយគឺឆ្ងាញ់ហើយ។

ខ៖ ជ្រក់ស្ពៃបើតាមនេះយើងគិតទៅ យើងលាងស្ពៃអោយស្អាតហើយដាក់ស្ពៃហាលថ្ងៃ។

ក៖ ចាំ អាស្ពៃយើងធំៗហ្នឹងមីងហេ?

ខ៖ ចាំ!!ស្ពៃយើងហ្នឹង។

ក៖ ចាំអាហ្នឹងគេហៅស្ពៃអីគេវិញ?

ខ៖ ស្ពៃគេហៅស្ពៃទូរឆាយ។

ក៖ ទូរឆាយ!!

ខ៖ចាំ!!យើងលាងវាអោយស្អាតអោយអស់ដីអស់អីហើយ យើងយកវាមកសំដិលថ្ងៃចោលអោយវារាងឡើងស្រពៀបទៅយកមកច្របាច់អំបិលទៅ ច្របាច់អំបិលហើយពូតទឹកអំបិលចេញញាត់ដាក់ចូលក្នុងពាង ដាំទឹកស្ករដាក់ចូលទៅ!!!

ក៖ អុឺចឹងស្ករហើយនឹងអំបិលដាំទឹកហ្នឹងលាយចូលគ្នាតែម្តង?

ខ៖ ចាំហ្នឹងហើយ ដាំទឹកអោយពុះ។

ក៖ហើយ!!

ខ៖ មិនបាច់កូរទេណាស់!!

ក៖ ចាំ!!ដាំអោយពុះហើយទុកអោយក្តៅ!!

ខ៖ អត់បាច់ អត់បាច់ទុកអោយត្រជាក់ទេ។

កះ ចាក់ទៅម៉ង?

ខះ ចា៎ ចាក់ទៅគឺស្ដែវាស្រួយល្អ!!

កះ ហ្ហ៎អញ្ចឹង វាអត់រលួយទេអ្នកមីងហោ?

ខះអត់ទេអត់រលួយទេ កព្រោះចាក់ទៅជាតិស្ដែវាត្រជាក់ជាមួយស្ដែវាច្រើនណាស់!!

កះហ្ហ៎!!

ខះពេលយើងចាក់ទឹកទៅវាល្មមហើយ។

កះ ហ្ហ៎អ៊ីចឹងទាំងពុះភ្លាមហ្នឹងចាក់ទៅតែម្ដងទៅ?

ខះ ហ្នឹងហើយ!!ហ្នឹងហើយ!!

កះអញ្ចឹងអ្នកមីងដូចរបៀបថាអាទឹកស្ដែជ្រក់ហ្នឹងដូចរបៀបថា
ពេលយើងភ្លក់ហ្នឹងអោយវាផ្អែមឬក៏អោយវាប្រៃ?

ខះ អោយវាប្រៃបន្តិច។

កះអោយវាប្រៃបន្តិចហោ?

ខះ ចា៎!!

កះ បើវាផ្អែមម៉េចទៅមីង?

ខះ បើផ្អែមពេកវាឆាប់ជូរ វាឆាប់ជូរវាឆាប់ដុះផ្សិត!!

កះចា៎!!

ខះហ្នឹងហើយ!!តែបើយើងអោយវាប្រៃតែបើយើងដាក់ស្ករដាំអោយវាពុះចូលគ្នាអាហ្នឹងវាអត់អីទេ!!ដល់តែពេលយើងស្ដែវាក្រហមល្អទៀតជ្រក់ហា៎ មិនបាច់ច្រើនលក្ខ័ទេ!!

កះចា៎!!

ខះ ក្រហមល្អម៉ង!!

ក៖ អើយអ្នកខ្លះវិញញ៉ុមទៅឃើញឡើងលឿង។

ខ៖ អាហ្នឹងប្រើលក្ខ័ហ្នឹង !!

ក៖ ហ្នឹងហើយ!!

ខ៖ មិនមែនប្រើធម្មជាតិដូចយើងណា!!

ក៖ ចា៎ ដល់ពេលអ៊ិចឹងមីងប៉ុន្មានថ្ងៃបានអាចយកទៅលក់បានទៅជ្រក់ស្ពៃ?

ខ៖ បើយើងភ្លក់បើវាល្មមជូរអាចយកលក់បានហើយអាហ្នឹងយើងយកទៅលក់ទៅ បើយើងអាកំនត់បានដាក់អំបិលវាជ្រុលវាមិនងាយជូរដែរណាស់!!

ក៖ហ៊ឺ!!

ខ៖ជួនកាលវាអត់ងាយជូរដែរ!!

ក៖ នៅសម័យហ្នឹងគេលក់មួយគីឡូប៉ុន្មានវិញមីង?

ខ៖ កាលពីជំនាន់ហ្នឹងថ្លៃដែរហ្នឹងជ្រក់ស្ពៃ យើងលក់ពីជំនាន់ហ្នឹងតែគ្រាន់តែថាវាមិនមែនថាថ្លៃដូចជាឥឡូវពេកក៏មិនដឹង ព្រោះពេលកាលហ្នឹងញ៉ុមឧស្សាហ៍ទៅផ្សារដែរតែញ៉ុមអត់ចាំហា៎!!

ក៖ចា៎!!

ខ៖ញ៉ុមអត់ចាំ។

ក៖ អញ្ចឹងម៉ាក់អ្នកមីងអើរជ្រក់ស្ពៃហើយ លក់ជ្រក់ស្ពៃហើយចិញ្ចឹមជ្រូកទៀត?

ខ៖ ហ្នឹងហើយ!!!ចិញ្ចឹមជ្រូក។

ក៖ ហ្ហ៎អញ្ចឹងទៀតហោ?អញ្ចឹងតទៀតបាន អូខេអ្នកមីងមានចាំអីគេទៀតពីម៉ែដែលចង់និយាយប្រាប់អីអត់?

ខ៖ អត់មានចង់អីគេទៀតទេ គ្រាន់ចង់និយាយថាគ្រាន់តែថាអើរតែប៉ុណ្ណឹង ដឹងតែប៉ុណ្ណឹងមកទេហើយគាត់ពីអាពត ហើយបែកអាពតហើយគាត់ចិញ្ចឹមកូនៗហ្នឹង!!

កៈចាំ!!

ខៈតែកំសត់តែហើយឪពុកញ៉ុមគេយកទៅសម្លាប់ចោលហ្នឹង
បែកគ្នារហូតហ្នឹងមកហើយគាត់ដូចថាគាត់ចេះតែទទូលដំណឹងអីចឹងគេចេះតែប្រាប់ហាំ!!ថាឮ
ឃើញនៅនេះនៅនោះថាចេះតែចាំមើលផ្លូវប្តីរហូតម៉ែញ៉ុមដូចគេថាដូចស្អីអញ្ចឹងដូចសិលាចាំ
ប្តីអីចឹង!!

កៈចាំ ប៉ុន្តែដឹងតែសម្លាប់ចោលហើយហី?

ខៈ ហ្នឹង!!

កៈ តែអត់ច្បាស់ទីហីមីងហី?

ខៈ
អត់ទេគេយកទៅសម្លាប់ចោលហើយប៉ុន្តែដូចថាគេអ្នកឃើញគេដូចថាស្រដៀងគេចេះតែមក
ប្រាប់យើងអញ្ចឹងទៅណាស់!!

កៈហ្នំ!!

ខៈគេថាជួបផុននៅនេះ
ហើយម៉ែញ៉ុមចេះតែចាំមើលចាំមើលអ្នកណាគេស្តីក៏អត់ហ៊ានយកដែរ!!

កៈហ៊ីៗ!!

ខៈរហូតទាល់តែស្លាប់ចាំប្តីគាត់!!

កៈ ពេលហ្នឹងមេម៉ាយអាយុប៉ុន្មានវិញយាយ?

ខៈ ម្តាយញ៉ុមគាត់អាយុ២០ជាង មេម៉ាយអាយុ២០ជាង។

កៈមេម៉ាយអាយុ២០ជាងទេ?

ខៈ ចាំអាយុ២០ជាងតើ!!

កៈ ស្រលាញ់ប្តីខ្លាំងណាស់ !!

ខ៖ ហ្នឹងហើយ។

ក៖ អត់មានព្រមយកស្វាមីទៀតទេ!!

ខ៖ ចុះបើគិតទៅគាត់អាយុ២៩ ២៩កូនប្អូនញ៉ុមចូលផុតពីឆ្នាំ៧៥(១៩៧៥)មកមើលគិតទៅខ្ញុំទឹមតែអាយុ៥១ទេគាត់កាលពីហ្នឹងមកញ៉ុមទឹមតែអាយុ៥១!!

ក៖ចា៎!!

ខ៖ហើយបើគិតមកដល់ឥឡូវគាត់អាយុ៧០ជាងហើយ។

ក៖ ចា៎!!អញ្ចឹងឥឡូវ មីងចាំថ្ងៃខែឆ្នាំកំណើតរបស់យាយទេ?

ខ៖ ញ៉ុមអត់ចាំផង ចាំតែឆ្នាំធម្មតា!!

ក៖ម៉េចវិញ?

ខ៖ ដឹងតែគាត់អាយុ៦០គត់ពេលគាត់ស្លាប់ហា៎!!!

ក៖ ពេលគាត់ស្លាប់២០០៩ហ្នឹង?

ខ៖ចា៎!!

ក៖ ឆ្នាំអីគេវិញមីង?

ខ៖ ម្តាយញ៉ុមឆ្នាំរកា។

ក៖ ចា៎អញ្ចឹងអ្នកមីងចូលដល់ឪពុកម្តង ឪពុកអ្នកមីងគាត់ឈ្មោះអីគេដែរ?

ខ៖ ឪពុកញ៉ុមគាត់ឈ្មោះធូ ភុន។

ក៖ ធូ ភុន!! គាត់ស្លាប់នៅក្នុងជំនាន់ប៉ុល ពត?

ខ៖ចា៎!!

ក៖មីងចាំថ្ងៃខែឆ្នាំកំណើតរបស់គាត់ទេ?

ខ៖ ញ៉ុមអត់ចាំទេ ចាំតែឆ្នាំធម្មតា បើថាឆ្នាំបារាំងញ៉ុមអត់ចាំទេ។

ក៖ ឆ្នាំខ្មែរគាត់ឆ្នាំអីគេវិញ?

ខ៖ គាត់ឆ្នាំថោះ។

ក៖ ចាំ!! ឥឡូវគាត់ស្លាប់១៩៧០ប៉ុន្មានអ្នកមីង?

ខ៖ កាលពីអាពតយកទៅសម្លាប់ហ្នឹងឆ្នាំ៧៨(១៩៧៨)។

ក៖ ឆ្នាំ៧៨(១៩៧៨)!! អាយុគាត់ប៉ុន្មាន?

ខ៖ ខ្ញុំមិនដឹងជាគាត់អាយុប៉ុន្មានទេពេលហ្នឹងអាយុប៉ុន្មានទេប៉ាញ៉ុមហិតែដឹងតែគេយកទៅសម្លាប់ចុងឆ្នាំ៧៨(១៩៧៨)ហ្នឹងម៉ង!!!

ក៖ចាំ!!!

ខ៖ គ្រាន់តែគេយកគាត់ទៅសម្លាប់ប្រហែលជាខ្វង់៦ខែហើយឬក៏ប៉ុន្មានខែទៀតណាមចូល !!ក៖ហ៊ឺ!!

ខ៖ ខុសត្រូវតែបន្តិចតើ!!

ក៖ ហ្នឹងហើយ ចាំតែមួយក្រឹកទៀតលែងអីបណ្តោយ!!

ខ៖ ហ្នឹងហើយ!!

ក៖ អ៊ីចឹងនៅពេលហ្នឹងម្តាយឪពុកអាយុប៉ុន្មានបង ឪពុកបងម្តាយអ្នកមីងប៉ុន្មានឆ្នាំ?

ខ៖ ខ្ញុំអើយបងប្រុសខ្ញុំមែន?

ក៖ អត់ទេឪពុករបស់អ្នកមីង !! ឪពុករបស់អ្នកមីងឈ្មោះអីគេមិញ?

ខ៖ ធូ ភុន។

ក៖ ហ្នឹងហើយតាភុនហ្នឹងហាំអាយុបងម្តាយរបស់អ្នកមីងប៉ុន្មានឆ្នាំ?

ខ៖ គាត់ដូចបង មើលគាត់ឆ្នាំថោះហើយឆ្នាំរកាដូចបងគ្នាច្រើនដែរហោ??

កៈ ចាំ!! មើលរកា ច្រើនឆ្នាំដែរហ្នឹងហាំ!!មើលញ៉ុមចង់បែកហើយនេះ!! ថោះ រោង ម្សាញ់ មមី មមែ វក រកា ៧ឆ្នាំអ៊ីចឹងគាត់បងរបស់យាយ៧ឆ្នាំ អ៊ីចឹងអោយគាត់ដកតាមហ្នឹងទៅ បើសិនជាយាយពេលស្លាប់អាយុ៧៩ណោះ?

ខៈ ៦០។

កៈ ៦០ ហើយឆ្នាំ២០០៤ អ៊ីចឹងតានៅហ្នឹងបង៧ឆ្នាំអញ្ចឹង៦៧ហើយ បើសិនជាគិតតាមហ្នឹងគេដកតាមហ្នឹងទៅគេដឹងដកតាមណាហើយ!!ហ្នឹងហើយដឹងពីអាយុគាត់ដឹងពីឆ្នាំអីវ៉ាន់អ៊ីចឹងទៅមីងណាស់!!

ខៈ ចាំ!!

កៈ គាត់អ្នកស្រុកមកពីណាឪពុកអ្នកមីង?

ខៈ គាត់អ្នកស្រុកនៅខាងតាកែវ។

កៈ នៅខាងខេត្តតាកែវ ស្រុកភូមិឃុំអីគេដែរមីង?

ខៈ ស្រុកអើយត្រាំកក់ មើលមើលមកខេត្តតាកែវ ស្រុកត្រាំកក់ ដើមរកា។

កៈ ភូមិដើមរកាហ្នឹងហោ?

ខៈ ចាំ!!

កៈ ហ្នឹងហើយ ស្គាល់ហើយផ្លូវទៅតាកែវទៅកំពតទៅអីហ្នឹង មីងចាំអនុស្សាវរីយ៍អីគេខ្លះជាមួយឪពុកពេលមីងនៅក្មេងអ៊ីចឹងហាំធ្លាប់ គាត់ជាមនុស្សម៉េចដែរ អ្នកមីងរៀបរាប់គាត់អោយអស់មើល?

ខៈ អនុស្សាវរីយ៍ពីក្មេងឪពុកខ្ញុំគឺជាមនុស្សល្អម្នាក់ទៅកន្លែងណាគឺគេចូលចិត្តកន្លែងហ្នឹង គាត់ដូចជាគាត់ធ្វើពេទ្យហាំ!!

កៈហ៊ឺៗ!!

ខ៖
ហើយគាត់មិនដែលមានសត្រូវឬក៏គាត់មានដែលល្អក់ដ្ឋានជាមួយបងប្អូនសូម្បីតែអ្នកជិតខាងក៏អត់ដែរ!!

ក៖ ហ៊ើៗ!!

ខ៖
ឪពុកខ្ញុំគឺជាមនុស្សល្អនិយាយរួមទៅតាំងពីជីដូនជីតាញ៉ុមមកម៉ងនៅក្នុងស្រុកនេះហ្នឹងអត់មានអ្នកណាដែលនិយាយពីឪពុកម្ដាយរបស់ញ៉ុមឬក៏ជីដូនជីតាញ៉ុមមកថាគាត់អាក្រក់ម៉េចគឺអត់ទេមានតែគេលើកសរសើរ!!

ក៖ចាំ!!

ខ៖ អឺចឹងណាស់!!តាំងពីតាទួត តាលួតញ៉ុមមក!!

ក៖គឺតែមនុស្សស្រួលទាំងអស់ម៉ងហោ?

ខ៖ ចាំ!!

ក៖ ឪពុកគាត់ធ្វើពេទ្យ?

ខ៖ ចាំគាត់ធ្វើពេទ្យ។

ក៖ ក្រៅពីធ្វើពេទ្យមានធ្វើអីគេទៀតទេអ្នកមីង?

ខ៖ ឪពុកញ៉ុមគាត់ជួយម្ដាយគាត់លក់នំបញ្ចុកលក់អីអាហ្នឹងកាលពេលអត់ទាន់បានចូលធ្វើពេទ្យហាំ!!

ក៖ចាំ!!

ខ៖ អាហ្នឹងញ៉ុមអត់ដឹងដែរតែគាត់និយាយហាំតែដល់ពេលគាត់បានម្ដាយញ៉ុមហើយនេះអាហ្នឹងគាត់បានធ្វើពេទ្យ
បានគាត់បានម្ដាយញ៉ុមនេះហាំ!!

ក៖ចាំ!!

ខ៖ គាត់ធ្វើពេទ្យ!!

ក៖ តែពេទ្យជំនាន់ហ្នឹង!!

ខ៖ ប៉ាខ្ញុំដុកទ័រ!!

ក៖ បានលុយច្រើនណាស់មីងហោ?

ខ៖ អត់ទេ លុយគេឥឡូវគេរកបាន ពេទ្យប៉ាញ៉ុមគឺពេទ្យគាត់សង្គ្រោះតែម្តង!!

ក៖ ស្មោះស្មគ្រ័ម៉ង!!

ខ៖ ចាំ ចង់អ្នកណាគេអោយ អ្នកណាគេនឹកឃើញគេអោយអោយទៅ បើអ្នកណាមិនអោយអោយទៅ!!

ក៖ ចាំហ្នឹងហើយ !! អ្នកមីង តាមពិតច្បាប់ពេទ្យហាំគឺត្រូវតែជួយសង្គ្រោះជីវិតមនុស្សជាធំ!!

ខ៖ ចាំ!!

ក៖តែសម័យឥឡូវអត់ទេ!!

ខ៖ គាត់មិនថាយប់ឧបសគ្គប៉ុន្មានទេគឺគាត់សង្គ្រោះជិះទៅខ្លួនឯងម៉ង!!

ក៖ហ៊ី១!!

ខ៖ត្រូវវះកាត់ត្រូវអី
ត្រូវឆ្លងទន្លេរួចមិនរួចអីគឺគាត់ជូនទៅខ្លួនឯងហើយទោះបីគ្រាប់ផ្លោងមកប៉ុន្មានក៏ដោយ
ហ្នឹងឪពុកខ្ញុំ។

ក៖ចាំ!!

ខ៖ គាត់អត់ដែលថាហ្ហំមានអីអញ្ចេះអញ្ចុះទេ គាត់សុខចិត្តបញ្ជូនទៅខ្លួនឯង!!

ក៖ចាំ!!

ខ៖ ធ្វើដោយដៃឯង!!

កះហ៊ឺៗ!!តែគាត់ស្លាប់ដោយសារស្លាប់នៅក្នុងជំនាន់ប៉ុល ពតហ្នឹង?

ខះ ចា៎នៅក្នុងជំនានន់ប៉ុល ពតហ្នឹង !!

កះ ដោយសារគេស៊ើបដឹងមីងហេ?

ខះ គេដឹង !! បើគិតទៅវាចង់ចូលឆ្នាំ៧៩(១៩៧៩)ហើយហ្នឹងហា៎!!នៅតែបន្តិចទៀតសោះ!!

កះ ហ្នឹងហើយ កុំអីមីងមិនមែនធម្មតាទេគ្រួសារណាស់!!

ខះ ចា៎!!

កះ ពេទ្យហា៎!!

ខះ បើសិនជាឪពុកញ៉ុមនៅក៏ញ៉ុមអត់ដុនដាបដល់ថ្នាក់ហ្នឹងដែរ!!

កះចា៎!!

ខះតែមិនដឹងនិយាយថាម៉េចអានេះ!!

កះ ចា៎ និយាយទៅមីងបន្ទាប់ពីសង្គ្រាមមកមួយដូចគេនិយាយថាចាប់ផ្ដើមពីឆ្នាំ០មកវិញហា៎!!

ខះចា៎!!

កះ ប្រទេសយើងហា៎!

ខះចា៎!!

កះ ចុះបើឡើងខ្ទេចខ្ទីអស់ហើយហ្នឹងប្រទេសយើងមនុស្សចេះដឹងមានអ្នកណាគេបង្កើតប្រទេសឡើងវិញមានតែបន្តិចបន្តួចនៅសល់មកហ្នឹង!!

ខះចា៎!!

កះបើមួយៗស្លាប់អស់ហើយហ្នឹង ពួកហ្នឹងវាសម្លាប់រង្គាលអស់ម៉ងអ៊ីចឹងពេលគេថាខ្មែរយើងពេលឆ្នាំ៧៩(១៩៧៩)ហ្នឹងមកគេថាកម្ពុជាចាប់ផ្ដើមពីឆ្នាំ០មកវិញមីងហា៎!!

ខ៖ ហ្នឹងហើយ។

ក៖
តាមពិតគេផ្សេងប្រទេសផ្សេងត្រូវយកគំរូពីប្រទេសយើងដើម្បីទៅអភិវឌ្ឍន៍ស្រុកគេទេអ្នកមីង
ហ្នឹង!!

ខ៖ ហ្នឹងហើយ!!

ក៖ ដោយសារពេលមុនខ្លាំងហ្វ៎!!

ខ៖ចាំ!!

ក៖ ដល់ពេលឥឡូវប្រទេសគេដល់ណាដល់ណីហើយយើងណេះនៅវេទនាហ្នឹង!!

ខ៖ហ្នឹងហើយ!!
តែគ្រាន់តែថាញ៉ុមអានិតឪពុកម្ដាយញ៉ុមគាត់គ្រាន់ថាតែប៉ុណ្ណេះឆាកជីវិតគាត់កំសត់មករហូត
បានមកចូលអាពតហ្នឹងគាត់បែកគ្នាគ្មានបាន
បើនិយាយរួមទៅភាពជាប្ដីប្រពន្ធអត់មានបានរស់នៅជាមួយគ្នាទេ គេបំបែកគាត់រហូត!!

ក៖ហ៊ឺ!!

ខ៖ឆ្នាំ៧៥(១៩៧៥)ដល់ឆ្នាំ៧៨(១៩៧៨)គេយកទៅសម្លាប់រៀងខ្លួនគិតមើលមើល!!

ក៖ហ៊ឺ!!

ខ៖ អត់មានមកបានជួបមុខប្រពន្ធកូនម៉េចទេ!! អត់អាលីងម៉ង!!

ក៖ អឺចឹងគ្រាន់តែបែកប៉ុល ពតភ្លាមខ្ទេចម៉ង!!

ខ៖ ក្នុងហ្នឹងហា សង្គមប៉ុល ពតហ្នឹងក្នុងឃុំសិត្បូយើងហ្នឹងពីមុនគេហៅភូមិសិត្បូ!!

ក៖ចាំ!!

ខ៖មហាកំពូលហើយ
ហើយកោះគរហ្នឹងហាំហ្នឹងហើយជាកន្លែងដែលគេយកមនុស្សទៅសម្លាប់
គេហៅមន្ទីរ១០៨ជំនាន់ហ្នឹង !!

ក៖ ០៧នៅទួលស្លែងមីងហេហីអី?

ខ៖ ខ្ញុំអត់ដឹងនៅណាទេ ប៉ុន្តែខ្ញុំដឹងថាកន្លែងកោះគរហ្នឹងកន្លែងមន្ទីរ១០៨គេពីអាពត។

ក៖សាហាវណាស់មីងហេ?

ខ៖
ចាំម្ដាយញ៉ុម(ប្រហែលជាឪពុកទេគាត់ច្រឡំនិយាយម្ដាយ)ក៏គេយកទៅសម្លាប់នៅហ្នឹងដែរ!!

ក៖ រង្គាលហ្នឹងម៉ង !!និយាយទៅគ្រាន់តែឆ្លងទឹកទៅដល់ម៉ងមីងហេ?

ខ៖ ចាំហ្នឹងហើយ!!ឆ្លងទឹកដល់ម៉ង!!

ក៖ចា!!!

ខ៖តែគេគេបែកគ្នាដែរ
តែគ្នាបានជុំគ្នាមួយយប់ឬក៏ពីរយប់ហាំតែចំនែកឪពុកខ្ញុំហើយម្ដាយខ្ញុំគឺអត់រលើងគ្រាន់តែគេចាប់បំបែកទៅមួយទៅខាងកំលាំងស្រួចមួយកងស្ត្រីមួយកងកម្លាំងកសិករនៅកងកំលាំងស្រួចហ្នឹង គឺបែករហូត បែករហូត!!

ក៖ គាត់អត់មានលួចមកជួបគ្នាអី?

ខ៖ អត់មានសោះអត់រលើងម៉ង។

ក៖ គឺមិនអាចមកបានម៉ង?

ខ៖
អត់អាចមកបានម៉ង!!ឪពុកខ្ញុំដេកឈឺនៅក្រោមដើមត្នោតគេអោយមើលគោនេះនៅបន្ទាយសេះនេះ!!

ក៖ហ៊ឹៗ!!

ខ៖ ផ្តាំអោយម្តាយញ៉ុមបានទៅជួបគ្នាបន្តិចហាំ អត់មានបានជួបគ្នាទៀត គ្រាន់តែដើរងាកទៅមើលគ្នាតែប៉ុណ្ណឹងទេ អត់មានហ៊ានជួបទេ។

ក៖អូយស្រណោះប៉ុន្មានទៅមីងអើយមីង!!

ខ៖ ចាំអត់មានបានថាជួបនិយាយគ្នាអត់កមានអាលីងម៉ង អត់សុទ្ធ!!

ក៖ហ៊ីយ៉ាប់ណាស់អាពួកអស់ហ្នឹង ធ្វើបាបគេដល់ករ។ អ៊ីចឹងមីងចូលដល់យាយម្តង យាយខាងម្តាយឈ្មោះយាយអីគេយាយ?

ខ៖ យាយញ៉ុមឈ្មោះយាយ សួស ប៉ុស។

ក៖ មីងកើតទាន់គាត់ទេ?

ខ៖ ញ៉ុមនៅទាន់តើ គាត់ស្លាប់ពេលនៅឆ្នាំ៩១(១៩៩១)។

ក៖ អាយុប៉ុន្មានគាត់ស្លាប់ហ្នឹង?

ខ៖ គាត់ស្លាប់អាយុ៨០។

ក៖ ៨០គត់អញ្ជឹង?

ខ៖ចាំ!!

ក៖ មីងគាត់អ្នកស្រុកមកពីណាវិញ?

ខ៖ គាត់អ្នកស្រុកហ្នឹងដែរ ស្រុកកំណើតនៅហ្នឹងដែរ។

ក៖ នៅកោះគរហ្នឹងដែរ !!

ខ៖ចាំ!!

ក៖ តែពេលមុនគេហៅឃុំសិត្បូរទេ!!

ខ៖ចាំ!!

ក៖មិនមែនឃុំរការខ្ពស់ហ្នឹងទេហោ?

ខ៖ រកាខ្ពស់តាំងពីដើមមក តែពេលជំនាន់អាពតគេបញ្ចូលគ្នាគេដាក់ឃុំសិត្ស។

ក៖ ហ្វ៎អ៊ីចឹងអាពតប្តូរតែពេលហ្នឹងទេហេ?

ខ៖ចា៎!!!

ក៖តែប៉ុន្មានឆ្នាំហ្នឹងទេ?

ខ៖ចា៎!!

ក៖មីងទាន់យាយយាយជាមនុស្សម៉េចដែរយាយ?

ខ៖យាយញ៉ុមក៏ជាមនុស្សល្អ
បើនិយាយទៅដូចញ៉ុមនិយាយប្រាប់អញ្ចឹងគាត់មួយក្រុមគ្រួសារគាត់មកម៉ាសំបុកត្រយុកគាត់មក គាត់មនុស្សល្អទាំងអស់!!

ក៖ហ៊ឺៗ!!

ខ៖នៅក្នុងស្រុកនេះ!!

ក៖ចា៎!!

ខ៖ ព្រោះអីខ្ញុំអញ្ចេះខ្ញុំហ៊ានាធានាអះអាង ព្រោះអីពេលដែលខ្ញុំធំដឹងក្តីពេលកាលណាមកខ្ញុំឮតែគេនិយាយពីម្តាយពីយាយពីម្តាយម៉ែខ្ញុំពីឪពុកតាខ្ញុំអញ្ចឹងទៅណាស់!!

ក៖ហ៊ឺ!!

ខ៖ពីឪពុកម្តាយខាងខ្ញុំហ្នឹងទៅ គេថារកគ្មានទេជាតិជាមនុស្សល្អរកគ្មានទេ ដូចតាទុនដូចយាយប៉ុសរកគ្មានទេហ្នឹងអាហ្នឹងហា៎ពេលញ៉ុមធំដឹងក្តីពេលណាមកទល់មកដល់សព្វថ្ងៃហ្នឹងឮតែគេនិយាយសរសើរមកគ្រប់គ្នាហា៎!!

ក៖ចា៎!!

ខ៖ ហើយជីតាញ៉ុមហ្នឹងស្លាប់ដោយសាររន្ទះបាញ់នៅចុងព្រៃកនេះ។

ក៖ ហើយគាត់អីក៏ម្លេះៗ!!

ខ៖ ហ្នឹងហើយចាំ!!

ក៖ អានិតគាត់ណាស់!!

ខ៖ តែដល់ពេលស្លាប់ដោយសាររន្ទះបាញ់ហ្នឹងហាំ ប្រពន្ធកូនទៅអត់ទាន់ទេ គឺពួកអ្នកស្រុក ចិន ចាម យួន គេទៅសែងយកមកដល់ផ្ទះអស់ហើយ គេយំគេស្រែកពីណោះមកហើយ ហ្នឹងហើយ!!

ក៖ដល់ពេលមនុស្សគាត់ល្អពេក។

ខ៖ ហ្នឹងហើយ!!

ក៖គេជួយ។

ខ៖ហ្នឹងហើយ
បានថាញ៉ុមបានថាញ៉ុមឮសួរតែគេហ្នឹងនិយាយអ៊ិចឹងហើយឮសួរដល់ខ្មោចយាយញ៉ុមនិយាយទៀត
ហើយជាពិសេសទៅទួលក្រសាំងហ្នឹងក៏ដោយចាស់នៅហ្នឹងជាពិសេសគេនិយាយគ្រប់គ្នាទាំងអស់ ដល់ពេលខ្ញុំទៅលេងអ៊ីចឹងទៅគេសួរញ៉ុមថាកូនចៅអ្នកណានិយាយអ៊ីចឹងហេកូនចៅតាទុនតើ!!សុទ្ធតែមិនធម្មតា
ហ្នឹងគេនិយាយអ៊ីចឹងណាស់!!ប៉ុន្តែអាហ្នឹងតាំងពីខ្ញុំដឹងក្តីមករហូតទល់សព្វថ្ងៃហ្នឹងគេលើកសរសើរពីយាយមករហូត។

ក៖ ហើយគាត់រកស៊ីអីគេវិញមីង?

ខ៖ យាយខ្ញុំតាខ្ញុំគាត់ដាំតែដំឡូង តែខ្ញីតាំងសង្គម ពីសង្គមចាស់មកពីដើមមក។

ក៖ ធ្វើតែចំការសុទ្ធតែម្តង?

ខ៖ ចាំគាត់ធ្វើតែចំការធ្វើស្រូវ។

ក ៖ចាំ!!២មុខហ្នឹង?

ខ៖ចាំ!!

ក៖ តែបានផលច្រើនៗណាស់អ្នកមីងហេពេលហ្នឹង?

ខ៖ ចាំ!!កាលជំនាន់ហ្នឹងមិនដូចយើងឥឡូវហ្នឹងទេ គាត់ធ្វើផលបាន!!!

ក៖ អ៊ីចឹងតាមិញឈ្មោះតាអីគេទុន?

ខ៖ ឈ្មោះ ឈ្មោះដឹងអីគេទុនទេ !!

ក៖ ដឹងតែឈ្មោះតាទុន?

ខ៖ ចាំ!!

ក៖ចាំអ៊ីចឹងតាអ្នកស្រុកអីវ៉ាន់!!អ្នកមីងនិយាយប្រាប់តិចមើលតាស្លាប់ដោយសាររន្ទះបាញ់អញ្ចឹងមីងហេ?

ខ៖ ចាំគាត់ស្លាប់ដោយសាររន្ទះបាញ់!!

ក៖ ចឹបានទៅដើមត្នោតវិញ?

ខ៖ គាត់មកពីបឹងគាត់មកពីចំការធ្វើស្រូវ។

ក៖ហ្ហ៎!!

ខ៖ ចាំហើយមេឃភ្លៀងហើយគាត់រន្ទះបាញ់នៅចុងព្រែកថ្កុលហ្នឹង។

ក៖ ហើយចុះវាមិនព្រមទៅឆេរនៅអាកន្លែងផ្សេងអញ្ចឹងទៅទេ!!

ខ៖ ញ៉ុមអត់ដឹងដែរទេណាស់ តែញ៉ុមក៏នេះដែរ គាត់ស្លាប់ដោយសាររន្ទះបាញ់ហ្នឹងតាំងពីម៉ែខ្ញុំមិនទាន់ការឯណោះ!!

ក៖ហ្ហ៎!!

ខ៖តែនិយាយតៗគ្នាមកហាំ!!

ក៖ចាំ!!

ខ៖ ចា៎ អឺចឹងញ៉ុមក៏នៅចាំអញ្ចឹងរហូតមក!!

ក៖ អូយអានិតគាត់ណាស់មីង!!

ខ៖ ចា៎ហើយដូចខ្មោចយាយញ៉ុមអីវ៉ាន់ហា៎គាត់និយាយអឺចឹងហា៎ ថាខ្មោចតាង៉ែងស្លាប់ហា៎គ្មានបងប្អូនណាទៅទាន់ទេ អ្នកស្រុកគេលីសែងយកមកដល់ផ្ទះមកយំអោយឡើងគ្រប់គ្នា!!

ក៖ ហើយម៉េចទៅមីង ហើយពេលហ្នឹងរន្ទះបាញ់ស្លាប់ហ្នឹង ខ្មៅឡើងពេញខ្លួន?

ខ៖ មិនដឹងដែរយើងអត់បានឃើញអត់បានអីដែរណាស់!!

ក៖ចា៎!!

ខ៖ដឹងពីជំនាន់ណាផងពេលហ្នឹងម្តាយខ្ញុំគាត់មិនទាន់មានគ្រួសារផង។

ក៖ កំពុងនៅឋានសួគ៌នៅឡើយ!!

ខ៖ ចា៎!!

ក៖ចា៎!!អឺចឹងមីងចូលដល់យាយតាខាងឪពុកវិញតាឈ្មោះអីគេដែរ?

ខ៖ តាខាងឪពុកញ៉ុមឈ្មោះឌុល។

ក៖អីគេឌុលវិញត្រកូលគាត់?

ខ៖ ខ្ញុំអត់ដឹងស្អីគេឌុលទេនេះ ខ្ញុំចាំតែឈ្មោះឈ្មោះទេ។

ក៖ ចា៎!!ហ្នំមិញភ្លេចសួរតាខាងម្តាយមិញគាត់អ្នកស្រុកមកពីណា?

ខ៖ តាខាងម្តាយមិញគាត់នៅខាងតាកែវដែរ ចា៎នៅតាកែវ។

ក៖ ចា៎ មីងមានដឹងពេលណាគាត់កើតអីអត់?

ខ៖ចា៎??

ក៖ ពេលណាគាត់កើតអីវ៉ាន់អញ្ចឹងទៅ!!ចាំឆ្នាំគាត់អីអត់?

ខ៖ ខ្ញុំអត់ចាំទេ គ្រាន់តែដឹងថាគាត់មកពីតាកែវ គាត់អ្នកស្រុកតាកែវ។

ក៖ ពេលគាត់ស្លាប់អាយុប៉ុន្មានមីងអត់ដឹងដែរហោ?

ខ៖ ញ៉ុមអត់ដឹងទេ។

ក៖ ចាំហ្នឹងហើយ អញ្ចឹងមិញចូលដល់ មិញតាហោ?

ខ៖ចាំ!!

ក៖ខាងឪពុកមិញ?

ខ៖ចាំ!!

ក៖តាម៉េចអីគេតាឌុលហោ?

ខ៖ ចាំតាឌុល។

ក៖គាត់អ្នកស្រុកនៅកោះគរហ្នឹងហេអ្នកមីងហោ?

ខ៖ តាញ៉ុមហ្នឹងគាត់នៅកោះគរហ្នឹងដែរ!!

ក៖ចាំ!!

ខ៖ចាំ!!

ក៖ អ៊ីចឹងតាឌុលខាងឪពុក?

ខ៖ ខាងឪពុក។

ក៖ ចាំមីងពេលមីងកើតទាន់តាឌុលទេ?

ខ៖ ញ៉ុមអត់ទាន់ដែរ។

ក៖តែដូចថាមុនប៉ុន្មានឆ្នាំអ៊ីចឹង!!

ខ៖ អត់អត់ទាន់។

កៈ អត់ដឹង អត់ដឹងថាមុនប៉ុន្មានឆ្នាំអីទេហោ?

ខៈ អត់ដឹង។

កៈ គ្រាន់តែដឹងឈ្មោះឪប្រាប់អីចឹងទៅ?

ខៈ គ្រាន់តែដឹងឈ្មោះចា៎។

កៈអ៊ិចឹងឪមានប្រាប់អីផ្សេងពីតាទៀតទេ?

ខៈ អត់មានប្រាប់អីទេ គ្រាន់តែគេនិយាយថាខាងតាខាងឪពុកញ៉ុមហ្នឹងគាត់ខូចរឿងស្រវឹង ថាអញ្ចឹងហា៎!!

កៈ ចា៎!!

ខៈ តាខាងឪពុកហ្នឹង គ្រាន់តែស្រវឹង តែស្រវឹងអត់មានធ្វើបាបអីអ្នកស្រុកទេ!!គ្រាន់តែថាខូចតែស្រវឹងទៅ ឡូឡាទៅតែអត់មានដែលធ្វើបាបធ្វើអីគេទេ!!

កៈហ៊ឺៗ!!

ខៈស្រវឹងអ៊ិចឹងគាត់ទៅជិះទូកជិះអីលេងអ៊ីចឹងទៅ!!

កៈ វរ វរ ធ្លាក់ទឹក។

ខៈ ហ្នឹងហើយ!!

កៈស្រវឹង ស្រវឹងស្ងួត។

ខៈ ហ្នឹងហើយចា៎!!

កៈ ការងារតាពីដើមគាត់ធ្វើអីគេអ្នកមីងដឹងទេ?

ខៈ គាត់ធ្វើតែស្រែចំការដូចតែជន្លងគាត់អ៊ីចឹង!!

កៈ ចុះយាយឈ្មោះអីគេវិញមីង?

ខ៖ យាយញ៉ុមឈ្មោះទី។

ក៖ អីគេវិញទី?

ខ៖ ដឹងស្អីគេទីទេ ព្រោះប្អូនតាញ៉ុម ប្អូនតាទុនញ៉ុមហ្នឹង!!

ក៖ចាំប្អូន!!

ខ៖ចាំ!!

ក៖ប្អូនជន្លងគ្នាអីចឹងហេ?

ខ៖ចាំ!!

ក៖អញ្ចឹងអត់ស្គាល់ដែរដោយសារមិញអ្នកមីងអត់ស្គាល់ត្រកូលតាទុនដែរ!!

ខ៖ចាំ!!

ក៖ មីងកើតទាន់យាយដែរតើហី?

ខ៖ ញ៉ុមកើតទាន់។

ក៖ មើលយាយម៉េចដែរមីងនិយាយប្រាប់មើល?

ខ៖ យាយហេ?

ក៖ចាំ!!

ខ៖ យាយមនុស្សគាត់ដូចថាគាត់មិនសូវរវីរវល់ជាមួយកូនជាមួយចៅទេ ចង់អ្នកណាធ្វើអីធ្វើទៅ បើនិយាយអោយចំរួមទៅយាយខ្ញុំហ្នឹងគឺគាត់ខាងស្រណុក !!

ក៖ហ៊ីៗ!!

ខ៖ស្រណុកសុខស្រួលម៉ង !!

ក៖ចាំ!!

ខ៖ គាត់អត់មានរវល់ទេ ចង់អាណាធ្វើអីធ្វើទៅ អាងតែខឹងឯរ ខឹងឯរ អីទៅបាត់អិចឹងម៉ង!!ហ្នឹងយាយញ៉ុមខាងប៉ាប៉ាញ៉ុម។

ក៖ ពេលហ្នឹងយាយមីងគាត់ស្លាប់ពេលអាយុប៉ុន្មានវិញ?

ខ៖ យាយញ៉ុមគាត់ស្លាប់ពេលអាពតដែរ មិនដឹងអាយុប៉ុន្មាន។

ក៖ មីងទាន់គាត់?

ខ៖ ញ៉ុមអត់ទាន់គាត់ទេព្រោះអីកាលហ្នឹង ចុះពីភ្នំពេញមកហ្នឹងមកស្រុកហ្នឹងជាមួយគ្នាដល់ហើយគាត់បែកទៅតាមកូនគាត់!!

ក៖ចាំ!!តែអត់ដឹងស្លាប់ឆ្នាំណាទេមីងហេ?

ខ៖ គាត់មិនដឹងស្លាប់ឆ្នាំណាទេ!!

ក៖ តែដឹងតែស្លាប់នៅក្នុងជំនាន់ប៉ុល ពតហ្នឹង?

ខ៖ចាំ!!គាត់ស្លាប់ជំនាន់អាពត ។

ក៖ តែពេលហ្នឹងគាត់ស្លាប់អាយុប្រហាក់ប្រហែលប៉ុន្មានអ្នកមីងតាមមើលទៅ?

ខ៖ យាយញ៉ុមកាលជំនាន់ហ្នឹងខ្ញង់ប្រហែលជា៥០ ៥០ហើយមើលទៅ!!

ក៖ ហ៊ឺ!!គេយកទៅសម្លាប់អ្នកមីងហេ?

ខ៖ អត់ទេគាត់ទៅតាមកូនគាត់ប្រហែលជាដាច់បាយហាំ ឈឺដាច់បាយកាលពីអាពតហ្នឹងហាំ!!ក៖ចាំ!!

ខ៖គេអត់យកទៅសម្លាប់ទេ ព្រោះអីចាស់ហើយគេអត់យកទៅទេប្រហែលជាគាត់ដើរទៅគាត់ទៅស្លាប់នៅស្រុកគាត់ហ្នឹង តាកែវណោះ!!

ក៖ ហ្វ៎អ៊ីចឹងទៅតាកែវណោះហើយមីងណោះ?

ខ៖ ចាំ!!

កះ នៅត្រាំកក់ហ្នឹងមីងណោះ?

ខះ នៅត្រាំខ្នារ ហាដើមរកា។

កះ ដើមរកាហ្នឹងហើយ!!

ខះ ដើររកាហ្នឹង!!

កះចាំ មីងសំរាប់បងប្អូនមីងទាំងអស់មានអ្នកណាគេទៅរស់នៅប្រទេសខាងក្រៅអីអត់?

ខះ អត់សោះ។

កះ អត់មានអ្នកណាគេខ្សែស្រលាយទៅមួយទេហេ?

ខះ មាន ខ្សែស្រលាយមួយម្ដាយមីងញុំមមួយប្អូនប៉ាញុំមពៅហ្នឹង។

កះចាំ!!

ខះប៉ុន្តែមិនដែលទំនាក់ទំនងអីមកទេ។

កះ នៅឯណាវិញអ្នកមីង?

ខះ នៅអាមេរិច។

កះ ចាំ!គាត់ទៅពេលបែកសង្គ្រាមហើយហ្នឹងហេ?

ខះ ចាំ!!បែកអាពតហើយ!!

កះ ចាំ គាត់ប្រហែលជានាំគ្នាទៅជំរុំហើយបានបានឡើងទៅណោះមីងហេ?

ខះញុំមអត់ដឹងដែរអើយម្ដាយមីងញុំមហ្នឹងម្ដាយមីងញុំមបង្កើតប្អូនពៅប៉ាញុំមបង្កើត!!

កះហ៊ឺៗ!!

ខះប៉ុន្តែញុំមអត់ដែលបានទំនាក់ទំនងអីទេ។

កះ បើសិនជាគាត់ចង់មករកក៏រកឃើញដែរ ដោយសារគាត់ស្គាល់!!

ខ៖ គាត់រកឃើញព្រោះអីអើរបានថារកឃើញ ពីព្រោះអីបានទទួលដំណឹងដឹងទៅមកដែរប៉ុន្តែគ្រាន់តែថាមិនដឹង ដូចថាគ្រាន់តែថាដឹង គ្រាន់តែថាបានត្រឹមតែម៉ាដឹងណាស់!!

ក៖ចា៎!!

ខ៖ ដូចថាទំនាក់ទំនងគ្នាផ្ញើរលុយផ្ញើរកាក់អីមកបងប្អូនកូនក្មួយគឺអត់ទេ។

ក៖ រៀងៗខ្លួនតែម្តង?

ខ៖ ចា៎!!ម្តាយមីង!!

ក៖ ចា៎អញ្ចឹងបានតែម្តាយមីងទៅមួយអញ្ចឹងមីងណោះ?

ខ៖ចា៎!!

ក៖ចា៎អញ្ចឹងអរគុណច្រើនអ្នកមីងដែលអោយញ៉ុមសំភាសន៍អំពីជីវិតរបស់អ្នកមីងក៏ដូចជាក្រុមគ្រួសារ
ហើយអ្វីទាំងអស់ហ្នឹងគឺកូនចៅបានស្តាប់ឮទៅថ្ងៃក្រោយនឹងអោយទៅដល់ពិភពលោកក៏ដូចជាមនុស្សជំនាន់ក្រោយអាចសិក្សាពីមនុស្សជំនាន់ហ្នឹងថាតើធ្វើអីខ្លះអ៊ីចឹងអ្នកមីងណាស់?

ខ៖ចា៎!!

ក៖ចា៎អរគុណច្រើន។